## Expressing disappointment at another’s misfortune



### អំពីការប្រកួតបាល់ទាត់

វីរៈ ៖ មានមើលបាល់ទាត់អត់យប់មិញ ?
តារា ៖ ថីមិនមើល ។ ខ្មែរប្រកួតជាមួយសាំងហ្គាពួរ ហ្នឹងមែន ?
វីរៈ ៖ ហ្នឹងហើយ ។ ស្តាយដល់ហើយ ។ ចាញ់ផិនណលធី (penalty) ចុងក្រោយ ។
តារា ៖ ហ្នឹងហើយ ។ ខ្ញុំសង្ឃឹមថាឈ្នះហើយហ្នឹងអំា ដឹងអី … ស៊យវិញ ។
វុទ្ធី ៖ ខ្ញុំបិទទូរទស្សន៍ចោលម៉ង ។ ខឹងពេក ។

### អំពីការប្រឡងចូលសាកលវិទ្យាល័យ

នារី ៖ កញ្ញា ម៉េចហ្នឹង ? ធ្វើមុខអីអីចឹង ?
កញ្ញា ៖ ប្រឡងលើកមុនធ្លាក់បាត់ហើយ ។ អត់បានចូលសាលាល្អបណ្តោយ ។
នារី ៖ កញ្ញាឯងខំប្រឹងរៀនប៉ុណ្ណឹងហើយធ្លាក់ទៀត! សាលាហ្នឹងអីក៏ពិបាកចូលម៉េះ ?
មិនដឹងត្រូវខំប៉ុណ្ណាទៀតទេ ។ ខ្ញុំស្តាយជំនួសកញ្ញាឯងម៉ងហើយនៀក ។
ហើយកញ្ញាឯងគិតម៉េចទៅអីចឹង ?
កញ្ញា ៖ អត់ទាន់ដឹងទេនារី ។

| | |
|---|---|
| វីរៈ តារា វុទ្ធី នារី កញ្ញា | M/M/M/F/F Cambodian names |
| ថីមិនមើល | colloquial for ហេតុអ្វីខ្ញុំមិនបានមើល, meaning: Of course I watched it! |
| ស្តាយដល់ហើយ | = ស្តាយមែនទែន = What a pity! |
| … ឈ្នះហើយហ្នឹងអំា | [I had hoped] they would win |
| ដឹងអី … ស៊យវិញ | Who could have known that it turned out so unfortunate … |
| ខ្ញុំបិទទូរទស្សន៍ចោលម៉ង | I switched off the TV immediately |
| ខឹងពេក | I was too angry |
| ម៉េចហ្នឹង ? | What’s wrong? |
| ធ្វើមុខអីអីចឹង ? | Why do you make such a face? |
| អត់បាន … បណ្តោយ | [I] won’t be able to … |
| … ម៉េះ | spoken form of … ម្ល៉េះ = why so? (expressing surprise) |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ស្ដាយជំនួស ... | to feel sorry/bad for ... |
| គិតម៉េចទៅអីចឹង ? | What are you going to do next? |

## Cultural notes

អសន្តិសុខនៅប្រទេសកម្ពុជា ធ្វើឲ្យមានរឿងទាក់ទងនឹងចោរកម្ម ឬគ្រោះថ្នាក់ចរាចរណ៍ជាច្រើនកើតឡើងជារៀងរាល់ថ្ងៃ ហើយការតាមដានព័ត៌មានទាំងនេះទាក់ទងនឹងហេតុការណ៍មិនល្អរបស់អ្នកដទៃតាមទូរទស្សន៍ឬនិយាយតៗគ្នា គឺជាទម្លាប់របស់ជនជាតិខ្មែរ គោលបំណងគឺដើម្បីដឹងពីមូលហេតុនិងបង្ការកុំឲ្យកើតឡើងចំពោះខ្លួនឯងឬមិត្តភក្តិក្រុមគ្រួសារ។

| | |
|---|---|
| អសន្តិសុខ | insecurity, lack of safety |
| ចោរកម្ម | robbery, theft |
| គ្រោះថ្នាក់ចរាចរណ៍ | traffic accident |
| ជារៀងរាល់ថ្ងៃ | every day |
| តាមដានព័ត៌មាន | to follow the news regularly |
| ហេតុការណ៍ = រឿង | event, incident |
| និយាយតៗគ្នា | to spread information by talking to each other |
| បង្ការកុំឲ្យ | to prevent sth. |

## Additional dialogue

ហេតុការណ៍ម៉ូតូត្រូវចោរលួច

តារា៖ កញ្ញា ឮថាកញ្ញាឯងត្រូវចោរលួចម៉ូតូអំ ?

កញ្ញា៖ ហ្នឹងហើយ បាត់ម្សិលមិញ។

តារា៖ ម៉េចបានបាត់ ? មានបានចាក់សោរកអត់ ?

កញ្ញា៖ កាលហ្នឹងខ្ញុំប្រញាប់ មានបានចាក់សោរកឯណា។ ថាចូលទិញអីញ៉ាំម៉ាភ្លែត ចេញមៅវិញអត់ឃើញម៉ូតូ។

តារា៖ ហើយមានប្ដឹងប៉ូលិសអត់ ? តែទោះប្ដឹងប៉ូលិស ក៏មិនងាយរកឃើញវិញដែរ។ ស៊យអាណោះ។ ហើយឥឡូវកញ្ញាឯងគិតម៉េចទៅ ? បានអីជិះ ?

កញ្ញា៖ បងប្រុសជូនទៅមៅម៉ារយៈសិន។

| | |
|---|---|
| ... អំ ? = ... ឬ ? | particle to form a question |
| ចាក់សោរក | to lock the key between the front wheel and the body of a motorbike |
| កាលហ្នឹងខ្ញុំប្រញាប់ | I was in a rush at that time |
| មានបាន ... ឯណា | didn’t ... |
| ស៊យអាណោះ | Such bad luck! |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.